# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 12-Apr-2019, 12:30
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ មេធាវីការពារក្ដីស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើម បណ្ដឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

**នៅចំពោះមុខ៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រ៊ីម ប្រធាន

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម Phillip RAPOZA

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ហុង គីមសួន
គឹម ម៉េងឃី
ឡោ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
សំ សុគង់
វ៉ែន ពៅ
ទី ស្រីនណា
Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Nushin SARKARATI
Mahesh RAI

ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន
នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ
Doreen CHEN
គង់ សំអុន
Anta GUISSÉ

## I. សេចក្តីផ្តើម

1. អង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណើពី ខៀវ សំផន និង នួន ជា ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០២ ("សំណើរបស់មេធាវីការពារក្តី")[1]។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមសង្ខេបក្នុងសំណុំរឿង ០០២/០២ នៅក្នុងអំឡុងពេលសវនាការជាសាធារណៈមួយ[2]។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ មានការជូនដំណឹងទៅដល់ភាគីទាំងអស់អំពីសាលក្រមដែលមានសំអាងហេតុពេញលេញ ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង[3]។ ហេតុនេះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមឆ្លើយតបដោយក្តីបារម្ភអំពីការប៉ះពាល់ដល់សិទ្ធិជាក់លាក់ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីសំណើរបស់មេធាវីការពារក្តី និងគោរពទៅតាមសុភវិនិច្ឆ័យរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងការសម្រេចទៅលើអង្គសេចក្តីនៃសំណើ។

## II. ច្បាប់ជាធរមាន

2. វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុងចែងថា "សេចក្តីសុំប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដូចមានកំណត់នៅក្នុងវិធាន ១០៥(៣) ត្រូវធ្វើក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងពីសាលក្រមនោះតាមករណីសមស្រប។ ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ [...]"។

---

[1] ឯកសារ F39/1.1 សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩។ ឯកសារ F40/1.1 សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់សេចក្តីជូនដំណឹង អំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩។

[2] សូមមើល ឯកសារ **E1/529.1** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[3] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (សេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញបានជូនដំណឹងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩)។

3. ពាក់ព័ន្ធនឹងវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់កាលពីមុនរួច ហើយថា "សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខគឺកម្រិតត្រឹមតែការបញ្ជាក់ ឬគ្រាន់តែពន្យល់ ត្រួសៗអំពីការលើកឡើងនូវកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្តីសម្រេចនេះមោឃៈ និងការលើក ឡើងនូវកំហុសអង្គហេតុដែល បណ្តាលឱ្យមានភាពអយុត្តិធម៌ ហើយពុំតម្រូវឱ្យមានការលើក ឡើងនូវទឡ្ហីករណ៍ ឬសំអាងផ្លូវច្បាប់នានាដើម្បីគាំទ្រឡើយ"[4]។

4. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានការអនុវត្តកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងឱ្យ បានឆាប់រហ័ស[5]។ វិធាន ២១(១)(ក) និង ២១(៤) នៃវិធានផ្ទៃក្នុង អានរួមគ្នា ចែងថា កិច្ចដំណើរ ការនីតិវិធី អ.វ.ត.ក ត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ហើយការសម្រេច សេចក្តីលើការចោទប្រកាន់ចំពោះមុខ អ.វ.ត.ក ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប[6]

---

[4] ឯកសារ F3/3 សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យាពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៨ (អង្គជំនុំជម្រះតុលាការកំពូលក៏បានពិចារណាផងដែរថា ទឡ្ហីករណ៍នេះអាចរួមបញ្ចូលផងដែរនូវសេចក្តីសម្រេចនានាដែលពុំតម្រូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ នៅក្នុងអំឡុងពេលជំនុំជម្រះ ដែលតម្រូវត្រឹមតែបញ្ជាក់ពីកំហុសដែលបានចោទប្រកាន់ប៉ុណ្ណោះ")។

[5] មាត្រា ៣៣ ថ្មី នៃច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី..." និង មាត្រា ៣៧ ថ្មី ចែងថា "ប្រការដែលបានចែងនៅក្នុងមាត្រា ៣៣ ៣៤ និង ៣៥ ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលការកំពូល"។ ឯកសារ F26/2/2 សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ ៧ (អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី "ទទួលបានសិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" និង "មានតួនាទីជាក់លាក់ និងមានកម្រិតនៅក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក")។

[6] សូមមើល ផងដែរ ឯកសារ E321/2 សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីប្រចាំការដោយតុលាការ សម្រាប់ ខៀវ សំផន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៤ ("អង្គជំនុំជម្រះមានកាតព្វកិច្ចធ្វើយ៉ាងណាឱ្យការជំនុំជម្រះប្រកបទៅដោយយុត្តិធម៌ និងឆាប់រហ័សដោយត្រូវពិចារណាលើផលប្រយោជន៍នៃយុត្តិធម៌ រួមទាំង ផលប្រយោជន៍របស់គ្រប់ភាគីទាំងអស់ផងដែរ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការពន្យារពេលយូរបន្ថែមទៀតនឹងនាំឱ្យមានផលប៉ះពាល់យ៉ាងច្រើន ក្រោយពីពិចារណាលើអាយុរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទនៅក្នុងរឿងក្តីនេះ។ អាស្រ័យហេតុនេះ វាចាំបាច់ដែល អ.វ.ត.ក ត្រូវប្រើប្រាស់ពេលវេលាដែលមានដើម្បីសម្រេចជាស្ថាពរលើបទចោទដែលនៅសេសសល់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន...")

។ វិធាន ១២*ស្ទួនពីរ*(១) និង (២) ចែងថា សហមេធាវីនាំមុខ "ត្រូវធានាឲ្យមានប្រសិទ្ធិភាពអំពីការរៀបចំការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក" និង "ត្រូវមានកាតព្វកិច្ចលើកកំពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាព"។

## III. សិទ្ធិ

5. នៅក្នុងសេចក្ដីសម្រេចលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ និងសាលដីកាក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិឆ្លើយតបទៅនឹងសារណានានា នៅក្នុងអំឡុងដំណាក់កាលនីតិវិធីបណ្ដឹងសាទុក្ខ[7] ប្រសិនបើសារណាទាំងនោះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី[8]។

6. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពីមុនរួចហើយថា ការយោងជាទូទៅ ទៅលើតុល្យភាពនៃសិទ្ធិរបស់ភាគី មានលក្ខណៈជាទូទៅពេក ពុំអាចតម្រូវឲ្យមានសិទ្ធិក្នុងការឆ្លើយតបក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមាន "សិទ្ធិទទួលបានសាលក្រមទាន់ពេលវេលា"[9]។

---

[7] ឯកសារ **F10/2** សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៤ និង ១៧ ("សេចក្ដីសម្រេចលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី")។ សេចក្ដីសម្រេចលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីសិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី យ៉ាងជាក់លាក់។ គោលការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌ ១៤ និង ១៧ នៃសេចក្ដីសម្រេចនេះ យកមកអនុវត្តចំពោះចម្លើយតប ផ្សេងៗទៀត។ សូមមើល ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១ ("នៅក្នុងសំណើនេះ អង្គជំនុំជម្រះយល់ស្របជាមួយ នួន ជា ត្រង់ចំណុចដែលថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពុំបានផ្ដល់មូលដ្ឋានគាំទ្រ ថាតើសារណា របស់ខ្លួនស្របតាមគោលការណ៍ដូចបានកំណត់នៅក្នុងយុត្តិសាស្ត្រមុនៗយ៉ាងដូចម្ដេចឡើយ ដូចជា ថាតើ សំណើរបស់ នួន ជា មានផលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួនយ៉ាងដូចម្ដេចឡើយ។ ការគ្រាន់តែយោងទៅលើភាពចាំបាច់ដើម្បីធានាបាននូវ "តុល្យភាពរបស់ភាគី" មានលក្ខណៈជាទូទៅពុំអាចបំពេញតាមលក្ខខណ្ឌតម្រូវ បើទោះបីជាដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានសាលក្រមទាន់ពេលវេលាក៏ដោយ")។

[8] ឯកសារ **F10/2** សេចក្ដីសម្រេចលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៧។

[9] ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១។

7. សំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំរយៈពេល ៦ខែ ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ហើយសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំរយៈពេល ៨ខែ ដើម្បីដាក់សេចក្តីជូនដំណឹងអំពី បណ្តឹងសាទុក្ខ[10]។ រយៈពេលដែលស្នើសុំឱ្យពន្យារនេះ នឹងប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបាននូវកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខឱ្យបានឆាប់រហ័ស និងទទួលបានសាលក្រមទាន់ពេលវេលា ជាពិសេសដោយពិចារណាទៅលើវ័យចាស់ជរា និងស្ថានភាពសុខភាពខ្សោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន។

## IV. **សារណា**

8. ដើមបណ្តឹងរដ្ឋប្បវេណីបានចាប់ផ្តើមចូលរួមកិច្ចដំណើរការនីតិវិធីចាប់តាំងពីឆ្នាំ ២០០៧។ តាំងពីពេលនោះមក សហមេធាវីនាំមុខបានដឹងក្រៅផ្លូវការអំពីមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨១នាក់ តាមរយៈមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ ឬតាមរយៈព័ត៌មានដែលផ្នែកសហមេធាវីនាំមុខប្រមូលបានដោយខ្លួនឯង[11]។ លើសពីនេះទៀត សហមេធាវីនាំមុខបានទទួលដំណឹងថា ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើនដែល មានសុខភាពទ្រុឌទ្រោមខ្លាំងមែនទែន ដោយសារតែជំងឺ ឬក៏វ័យចាស់ជរា មិនអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ឬក៏វេទិកាផ្តល់ព័ត៌មាននានាបានឡើយ។

9. សហមេធាវីនាំមុខ ពុំជំទាស់ទៅនឹងការពន្យារពេលសមហេតុផល ដែលអាចចាំបាច់ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះឡើយ ប៉ុន្តែស្នើសុំថា រាល់ការពន្យារពេលណាមួយនោះ ត្រូវពិចារណាទៅលើសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស ដោយ

---

[10] ឯកសារ **F40/1.1** សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែម សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពី បណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៦១។ ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៤៤។

[11] បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៣នាក់ បានទទួលអនិច្ចកម្មរួចមក ការស្នើសុំតាំងខ្លួនជាសិទ្ធិវន្តត្រូវបានដាក់ជូនដើម្បីបន្តបណ្តឹងរដ្ឋប្បវេណីដោយសាច់ញាតិរបស់ពួកគាត់។ សហមេធាវីនាំមុខកត់សម្គាល់ថា សាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលអនិច្ចកម្មភាគច្រើន ពុំទាន់បានផ្តល់នូវលិខិតបញ្ជាក់ពីមរណភាពនៅឡើយទេ។

គិតទៅដល់វ័យជរា និងបញ្ហាសុខភាពរបស់ពួកគាត់ និងតម្រូវការសម្រាប់អនុវត្តកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស។

10. សហមេធាវីនាំមុខ សូមទុកជូនអង្គជំនុំជម្រះតុលាការកំពូល សម្រេចតាមឆន្ទានុសិទ្ធិដ៏ត្រឹមត្រូវរបស់ខ្លួន ទៅលើសំណើសុំរបស់មេធាវីការពារក្តី ទាក់ទងនឹងការស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ។

## V. សំណើ

**អាស្រ័យហេតុនេះ** ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយក្តីគោរពឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

(១) **ពិចារណា** ទៅលើសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលធ្វើការសម្រេចលើអង្គសេចក្តីនៃសំណើរបស់មេធាវីការពារក្តី។

សូមលោកចៅក្រមមេត្តាទទួលយកចម្លើយតបនេះដោយក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |